## ប្រភេទនៃប័ណ្ណបើកបរ

ល័ក្ខខ័ណ្ឌផ្សេងៗទាក់ទងនឹងប័ណ្ណបើកបរត្រូវកំណត់ដូចខាងក្រោម:

**ប្រភេទ ក១ :** (អាយុ១៦ឆ្នាំយ៉ាងតិច) សម្រាប់ទោចក្រយានយន្តមានទំហំស៊ីឡាំងចាប់ពី ៤៩ ដល់ ១២៥សង់ទីម៉ែត្រគូប ។

**ប្រភេទ ក២ :** (អាយុ១៨ឆ្នាំយ៉ាងតិច) សម្រាប់ទោចក្រយានយន្តមានទំហំស៊ីឡាំងលើសពី ១២៥សង់ទីម៉ែត្រគូប ត្រីចក្រយានយន្ត និង ទោចក្រយានយន្តមានសណ្តោង ។

**ប្រភេទ ខ :** (អាយុ១៨ឆ្នាំយ៉ាងតិច) សម្រាប់រថយន្តដឹកអ្នក ដំណើរមិនលើសពី ០៩នាក់ ដោយគិតទាំងអ្នកបើកបរ និងរថយន្ត ដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥តោន ។

**ប្រភេទ គ :** (អាយុ២២ឆ្នាំយ៉ាងតិច) សម្រាប់រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥តោន ។

**ប្រភេទ ឃ១ :** (អាយុ២២ឆ្នាំយ៉ាងតិច) សម្រាប់រថយន្តដឹកអ្នក ដំណើរចាប់ពី ១០ ទៅ ២០នាក់ ដោយគិតទាំងអ្នកបើកបរ ។

**ប្រភេទ ឃ២ :** (អាយុ២៤ឆ្នាំយ៉ាងតិច) សម្រាប់រថយន្តដឹកអ្នកដំណើរលើសពី ២០នាក់ ដោយគិតទាំងអ្នកបើកបរ ។

**ប្រភេទ ង :** សម្រាប់រថយន្តប្រភេទ ខ គ និង ឃ មានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាលើសពី០,៧៥តោន ត្រូវចែកជាបីប្រភេទគឺ ប្រភេទ **ង**(ខ) ប្រភេទ **ង**(គ) និងប្រភេទ **ង**(ឃ) ។

- អ្នកមានប័ណ្ណប្រភេទ **ក២** អាចបើកបរយានយន្តប្រភេទ **ក១**បាន
- អ្នកមានប័ណ្ណប្រភេទ **ខ** អាចបើកបរយានយន្តប្រភេទ **ក១** យានយន្តកសិកម្ម ឬយានយន្តឧបករណ៍ ដែលមានល្បឿនអតិបរមាមិនលើសពី ៤០គីឡូម៉ែត្រក្នុងមួយម៉ោងតែមិនអាចបើកបរយានយន្តប្រភេទ**ក២** ឬ **គ** ឬ **ឃ១** ឬ **ឃ២** ឬ **ង** បានទេ ។
- ដើម្បីមានសិទ្ធិប្រឡងយកប័ណ្ណបើកបរប្រភេទ **គ** ត្រូវមានប័ណ្ណបើកបរប្រភេទ **ខ** ឬ **ឃ១** សិន ។
- អ្នកបើកបរយានយន្តប្រភេទ **គ** ឬ **ឃ១** ឬ **ឃ២** អាចបើកបរយានយន្តប្រភេទ **ខ** បាន ។

**ច្បាប់ចរាចរណ៍ថ្មីចូលជាធរមាន**

**តាំងពីខែមិនា ឆ្នាំ២០០៧។**

**ការផាកពិន័យចាប់ផ្តើម**

**ពីខែកញ្ញា ឆ្នាំ២០០៧ តទៅ។**

# គោរពច្បាប់ចរាចរណ៍ បើកបរមានសុវត្ថិភាព



## ដើម្បីជីវិតអ្នក គ្រួសារអ្នក និងអ្នកដទៃ



បើកបរមិនពាក់ខ្សែក្រវាត់សុវត្ថិភាព ឬមួកសុវត្ថិភាព ជាអំពើល្មើសច្បាប់ ។




បើកបរហួសល្បឿនកំណត់ ជាអំពើល្មើសច្បាប់ ។




បើកបរក្នុងពេលស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០.២៥ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០.៥ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ជាអំពើល្មើសច្បាប់ ។



ការផ្ទុកមនុស្សលើសចំនួនកំណត់ ឬផ្ទុកទំនិញលើដំបូលរថយន្តដែលមានកំពស់លើសពី ០.៥ ម៉ែត្រ ជាអំពើល្មើសច្បាប់ ។

# បទល្មើស និង ការផាកពិន័យ

| បទល្មើស | បទល្មើសមួយចំនួនដែលកំណត់ជាបទល្មើស | ទោចក្រយានយន្ត | រថយន្តធុនស្រាល | រថយន្តធុនធ្ងន់ |
|---|---|---|---|---|
| ថ្នាក់ លេខ ១ | - បើកបរដោយមិនពាក់ខ្សែក្រវាត់ ឬមួកសុវត្ថិភាព<br>- ឈប់ ឬចតដោយរំលោភ ឬរំខាន<br>- ប្រើទូរស័ព្ទក្នុងពេលបើកបរដោយគ្មានឧបករណ៍ភ្ជាប់ទំនាក់ទំនង<br>- បើកបរដោយកុងទ័រល្បឿន មិនដំណើរការ<br>- បើកបរហួសល្បឿនកំណត់ចាប់ពី ១ ដល់ ១៩ គ.ម/ម៉ោង | ៣ ០០០រៀល | ៥ ០០០រៀល | ១០ ០០០រៀល |
| ថ្នាក់ លេខ ២ | - អំពើល្មើសទាក់ទងនឹងការរៀបចំតាក់តែងបរិធានបើកបរ<br>- អំពើល្មើសទាក់ទងការរៀបចំដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានជំនិះមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>- ការផ្ទុកទំនិញមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>- បើកបរហួសល្បឿនកំណត់ចាប់ពី ២០ ដល់ ២៩ គ.ម/ម៉ោង | ៤ ០០០រៀល | ៨ ០០០រៀល | ១៥ ០០០រៀល |
| ថ្នាក់ លេខ ៣ | - បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ ឬក្រហមភ្លឹបភ្លែតៗ<br>- អំពើល្មើសទាក់ទងនឹងអាទិភាពនៅផ្លូវប្រសព្វ<br>- បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់<br>- មិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់ភ្នាក់ងារនគរបាលចរាចរណ៍<br>- បើកបរដោយពុំមានលិខិតត្រួតពិនិត្យលក្ខណៈបច្ចេកទេសយាន<br>- បើកបរហួសល្បឿនកំណត់ចាប់ពី ៣០ ដល់ ៣៩ គ.ម/ម៉ោង | ៥ ០០០រៀល | ១០ ០០០រៀល | ២០ ០០០រៀល |
| ថ្នាក់ លេខ ៤ | - បើកបរដោយមានអត្រាជាតិអាល់កុលចាប់ពី០.២៥ទៅ ០.៣៩ មីលីក្រាម ក្នុងមួយលីត្រខ្យល់<br>- ប្រើប្រាស់ប័ណ្ណបើកបរមិនត្រូវតាមប្រភេទយានជំនិះ<br>- ការបត់ឆ្វេង ឬស្តាំមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ<br>- បើកបរហួសល្បឿនកំណត់ចាប់ពី ៤០គ.ម/ម៉ោងឡើងទៅ<br>- ផ្ទុកមនុស្សលើសចំនួនកំណត់ | ៦ ០០០រៀល | ១២ ០០០រៀល | ២៥ ០០០រៀល |